


# សន្តិភាព និង ឯករាជ្យ ជា អត្ថភាព នៃ ប្រជាជាតិខ្មែរ

**Paix et indépendance, conditions de l'existence de la nation khmère**

## បុព្វកថា

បារមីខ្មែរ គឺ សន្តិភាព និង ឯករាជ្យប្រជាជាតិខ្មែរ។ ឯករាជ្យជាតិនេះ ដែលខ្មែរម្នាក់ៗ ត្រូវនាំគ្នា ការពារវា ឥតឈប់ឈរ។ ការការពារ វាជា ឆន្ទៈនយោបាយជាតិ ញុំាអោយចង់ធ្វើ តាមឧបនិស្ស័យសាកល គឺ កសាង សន្តិភាព ទាំង ខាងក្នុង និង ក្រៅប្រទេស។ នៅក្នុង ប្រវត្តិសាស្ត្រ ស្រុកខ្មែរ មានស្នាមសង្គ្រាមញឹកញយ ជាមួយ ប្រទេសជិតខាងខ្លួន និង សង្គ្រាមស៊ីវិល, ធ្លាប់ មាន ជោគជ័យ និង បរាជ័យ ចំពោះមុខ បរទេស, រីឯ សង្គ្រាមស៊ីវិល ជួនកាល មាន រូបភាពជាសង្គ្រាមបង្រួមបង្រួមជាតិ ជួនកាលជាសង្គ្រាមដណ្តើមអំណាចរវាងពួកអ្នកដឹកនាំ។ សួរថា ក្រោយពីសង្គ្រាមម្តងៗ តើ អ្នកដឹងនាំជាតិខ្មែរ ចេះកសាង សន្តិភាព ដើម្បី ពង្រឹង ឯករាជ្យជាតិ បានដែរឬទេ ?

## សន្តិភាព

បច្ចុប្បន្នកាលនេះ ស្រុកខ្មែរ ជាប្រទេសគ្មានសង្គ្រាម តាមការអនុវត្តន៍ កិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា ឆ្នាំ ១៩៩១ នាំមកនូវសន្តិភាព ជាទីស្រឡាញ់ ជាទីបំផុត ដើម្បីខ្មែរ ម្ល៉ោះហើយ វាជា សន្តិភាព តែមួយគត់ និង អវិភាគីយ។ សន្តិភាព ត្រូវចង្វាក់ជាមួយ សន្តិសុខសង្គម ដូច្នេះ ល្គឹកណា នៅក្នុងសង្គមគ្មាន យុត្តិធម៌ និង សមភាព ក៏វាគ្មានសន្តិភាពនោះដែរ។ នៅ

ក្នុងសន្តិភាពពិត វាមិនអាចមាន សុវត្ថិភាព សំរាប់តែ មនុស្ស មួយក្រុម តែ អស់គេ (les autres) មានទុក្ខ ដោយសារ វងគ្រោះ នឹង អយុត្តិធម៌ គ្រប់បែបយ៉ាង។ ដើម្បី រក្សាសន្តិភាព ជួនកាល គេត្រូវប្រើ មធ្យោបាយសង្គ្រាម ក្នុង តក្ក[1] (logique) នៃ សន្តិភាព គឺត្រូវមាន គោលបំណង មិនមែន ជា ការធ្វើទុក្ខបុកម្នេញ ដល់ប្រជាពលរដ្ឋ ដើម្បី បំរើ ប្រយោជន៍ បក្សពួក តែជា ការស្ម័គ្រចិត្តកំណត់[2] ផ្តល់នូវ គុណប្រយោជន៍ ដល់សន្តិភាព សំរាប់ប្រជាពលរដ្ឋ។ ជួនកាល គេត្រូវប្រើ សមរកម្ម នៃ គំនិត[3] ដោយយកចិត្តទុកដាក់ជាទីបំផុត រវាង ការទំនាស់ នឹង ន័យខុសគ្នា[4] ព្រោះសមរកម្មនេះ គឺ ដើម្បី រកដំណោះស្រាយ នៃ វិបត្តិ ផ្តល់នូវគុណប្រយោជន៍ ដល់សន្តិភាព នោះដែរ។ ព្រោះថា ការទំនាស់ ក្នុង តក្ក នៃ សន្តិភាព ត្រូវមាន ទិស្សមានភាព (visibilité) នៃ គំរិត ដែល លើសអំពី គំរិតនេះ នាំអោយ សមរកម្ម នៃ គំនិត ក្លាយជា ការប្រមាទគ្នា តាមធម្មតា។ មធ្យោបាយ ទាំងពីនោះ ត្រូវចាំបាច់គោរព នូវ គោលការណ៍ នៃ

---

[1] តក្ក ជា ពាក្យ សំស្រ្កឹត មានន័យថា ទឹកដោះជូរឡើងពពុះ ឬ គោរសផង។ ខ្មែរ យើង យកមកប្រើក្នុងពាក្យ តក្កវិជ្ជា ដែលជា វិជ្ជា ឬ ចំណេះខាងពិចារណារិះរកហេតុផល (logique)។ ជនជាតិសៀម គេយក ពាក្យ logique មកបកប្រែជាភាសាគេថា ពររក: (តក្ក) នាំអោយ Google យកមកបកប្រែជាភាសា ថា តក្ក ក្នុងការបកប្រែរបស់គេ ព្រោះខ្វះពាក្យនេះនៅក្នុងភាសាខ្មែរ។ ដូច្នេះ យើងយកពាក្យ តក្ក មកប្រើជាបណ្តោះអាសន្ន ក្នុងន័យ logique ចាំអ្នកប្រាជ្ញខ្មែរខាងអក្សរសាស្រ្ត សម្រេចយកពាក្យណាមួយសំរាប់បកប្រែពាក្យ logique នេះ។ តែចំពោះយើង ខ្មែរអាចយកពាក្យ ‹សមហេតុផល› មកប្រើក៏ដូចជាសមហេតុផលដែរ។

[2] ការស្ម័គ្រចិត្តកំណត់ ; engagement déterminé et résolu។

[3] សមរកម្ម នៃ គំនិត ; combat des idées។

[4] ការទំនាស់ នឹង ន័យខុសគ្នា ; la contradiction et la nuance។

ស្នេហាមនុស្សជាតិ[5] ហើយ ត្រូវចេះបង្រ្កាប នូវ ការបារម្ភ និង សេចក្តីមន្ទិល គ្រប់បែបយ៉ាង ដែលនាំ រំខានដល់ការកសាង សន្តិភាព លើផ្លូវ លទ្ធិប្រជាធិបតេយ្យ។

## ឯករាជ្យជាតិ

នៅស្រុកខ្មែរ សន្តិភាព ត្រូវចាំបាច់រួមនឹង ឯករាជ្យជាតិ ដើម្បី សម្តែង សក្តិយស របស់ខ្លួន ព្រោះថា បារមីខ្មែរ គឺ ឯករាជ្យជាតិ ហើយ អត្តសញ្ញាណ នៃ ស្រុកខ្មែរសព្វថ្ងៃ គឺ សន្តិភាព ក្នុងក្រប ខណ្ឌ កិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា ឆ្នាំ ១៩៩១។ តែដោយ អកុសល កិច្ចព្រមព្រៀងនេះ កំពុងក្លាយជា កម្រងអនុស្សាវរីយ៍ នៃ អតីតកាល ហើយ សព្វថ្ងៃ ប្រជាពលរដ្ឋខ្មែរ ហាក់បីដូចជា មិនជ្រើសរើសផ្លូវ ជា អ្នកក្លាហាន ដើម្បី ការពារ ឯករាជ្យជាតិ ខ្លួន ដែលនាំអោយស្រុកខ្មែរ ជាប់នៅក្នុងសំណាញ់ ដែលខ្លួន ឯងជា អ្នកត្បាញដោយខ្លួនឯង។ តើ វាស្ថិតនៅទីណា បារមីខ្មែរ មហានគរ ដែល ខ្មែរ (les Khmers) តែងតែ អនួងហៅ សំរាប់ បង្ហាញ មោទនភាព ជាតិខ្លួន ?

ខ្មែរ អាចបន្តរស់ ក្នុងរូបបំភាន់ភ្នែក ថាប្រទេសខ្លួន មាន ឯក រាជ្យ មាន សន្តិភាព ព្រោះមាន ការអភិវឌ្ឍន៍ នៃ សេដ្ឋកិច្ច និង ពុទ្ធិព្រឹទ្ធ[6] តែផលា របស់វាទាំងពីរ គ្មានមាន តម្លៃ នៃ សិទ្ធិ មនុស្ស និង លទ្ធិប្រជាធិបតេតយ្យ នាំបង្កើត ភាពចម្រូងច

[5] កាគោលការណ៍ នៃស្នេហាមនុស្សជាតិ ; principe philanthropique។

[6] ការអភិវឌ្ឍន៍ នៃ សេដ្ឋកិច្ច និង ពុទ្ធិព្រឹទ្ធ ; développement de l'économique et de l'intelligence។

ម្រាស់ នៃការពិត របស់ប្រទេស គឺ សេដ្ឋកិច្ចខ្មែរ ជា វេទី សំរាប់ ពួកឈ្មួញបរទេស ស្វែងរងតែចំណេញ ដល់សេចក្ដីវិនាស នៃ ន រតម្លៃ រឺឯ ពុទ្ធិព្រឹទ្ធ វិញ គ្មានមានមូលដ្ឋាន នៃ តម្លៃជាតិ ដែល នាំអោយយុវជន ក្លាយជា ហ្វូងមនុស្ស រស់នៅក្នុង ក្រោល នៃ ហត្ថពល តម្លៃថោក សំរាប់តែបំរើ ពួកពាណិជ្ជវិស័យ។

នយោបាយ នៃ ឯករាជ្យជាតិ របស់ ពួកអ្នកដឹកនាំសព្វថ្ងៃ បញ្ចេញអោយឃើញ នូវ អកុសល ជម្រៅ គឺ នយោបាយ នៅក្នុង កណ្ដាប់ដៃវៀតណាមទាំងស្រុង ដែលនាំអោយស្រុកខ្មែរបាត់ ឯករាជ្យជាតិ។ ក្រោយពី កិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា ឆ្នាំ១៩៩១ ហាក់បីនាំមកនូវ សេចក្ដីសង្ឃឹមជាថ្មី នៃការទំនាក់ ទំនង ស្មោះពិត រវាង ស្រុកខ្មែរ នឹង វៀតណាម។ តែ សេចក្ដី សង្ឃឹមនោះ វារលាយខ្យល់ ព្រោះ អ្នកដឹកនាំខ្មែរ គ្មាន សម្ថភាព នឹងគិតពិចារណាអោយច្បាស់ អំពី យុទ្ធសាស្ត្រ សំរាប់ការពារ ឯករាជ្យជាតិ ចំពោះមុខវៀតណាម និង នៅក្នុង ក្របខណ្ឌ ពិភពលោកូបនីយកម្ម។ នយោបាយ ពួកអ្នកដឹកនាំ មិនគិត ប្រមូលកម្លាំងជាតិ ដើម្បី ការពារឯករាជ្យជាតិ បែរជាតាង យកនយោបាយ យកកម្លាំងបរទេស ដើម្បី ការពារ អំណាច និង រក្សា បុព្វសិទ្ធិ បក្សពួក និង វណ្ណៈ ដែលជា កត្តា នាំអោយ របបនយោបាយចាស់ហួសសម័យ និង ផ្ដាច់ការ រស់ឡើងវិញ ហើយក្លាយជា តួធំចម្បង នៃ នយោបាយជាតិ។ ប្រតិសន្ធិ នៃ របបនយោបាយ នៃជរាភាពនោះ ជួយដល់កម្លាំងបរទេស ជា ពិសេស ចិន/យួន ជាកុម្មុយនិស្ត វាយបំបាក់កម្លាំងជាតិ ក្នុង

នាម នៃការអភិវឌ្ឍន៍ ដែលជា អន្ទាក់មរណៈ នៃប្រជាជាតិខ្មែរ ព្រោះ វាជា ការអភិវឌ្ឍន៍ព្រៃផ្សៃ នាំបំផ្លាញ ធនធានធម្មជាតិ និង នាំអោយសេដ្ឋកិច្ចជាតិ រស់នៅក្នុងដែនអំណាចបរទេស។

ស្រុកខ្មែរសព្វថ្ងៃ ជា ប្រទេស ថយកម្លាំងកាយនិងចិត្ត, មាន ប្រព័ន្ធយុត្តិធម៌ ជាអយុត្តិធម៌, មាន ក្រុមអ្នកនយោបាយ អប្បបញ្ញា, មាន វប្បធម៌ខ្ពង់ខ្ពស់ តែខ្វះ អ្នកឆ្នៃប្រឌិត អោយរស់រវើក, មាន ពួកអ្នកដឹកនាំ កើតដំបៅពុករលួយ យកអំពើហិង្សា ជា មធ្យោបាយដឹកនាំជាតិ នាំអោយ ប្រជាពលរដ្ឋនឿយណាយកម្លាំងចិត្ត, មាន ប្រជាជនរាប់សែននាក់ ចំណាកស្រុក ស្វែងរក ការងារធ្វើនៅបរទេស ដើម្បី រស់រស់ គ្មានពន្លឺអនាគត, មាន ប្រជាជនយួន រាប់លាននាក់ មករស់នៅ ដោយអនាធិបតេយ្យ។ នៅក្នុងសភាពបែបនេះ តើខ្មែរ នៅមានកម្លាំងជាតិអ្វី សំរាប់ការពារឯករាជ្យជាតិខ្លួនបាន ?

## សេចក្តីសន្និដ្ឋាន

តែខ្មែរ ភាគច្រើននៅមាន អារម្មណ៍ជ្រៅថា ជាតិនិយម នៅតែជា ឧត្តមកម្លាំង សំរាប់ការពារ សន្តិភាព និង ឯករាជ្យជាតិ ទោះបី បញ្ហា នៃ សន្តិភាព នៅក្នុងស្រុកសព្វថ្ងៃ ធ្វើអោយទៅជាឥតផល សំរាប់ប្រជាជាតិខ្មែរ យ៉ាងណាក៏ដោយ។ ម្លោះហើយនៅចំពោះមុខគ្រោះថ្នាក់ យួនូបនីយកម្ម និងអំណាចផ្តាច់ការ, ខ្មែរម្នាក់ៗ ត្រូវមាន ការបញ្ជាក់ នៃ អត្តសញ្ញាណជាតិ អោយបានច្បាស់លាស់ នៅក្នុង អារម្មណ៍ ដើម្បី អោយខ្លួនឯង ស្គាល់

ខ្លួនឯងច្បាស់ និង យល់ដឹង អំពី ប្រយោជន៍ជាតិ នៅក្នុងសន្តិភាព និង ឯករាជ្យជាតិ ក្នុងរូបបំភាន់ភ្នែកសព្វថ្ងៃ។ កម្លាំងប្រឆាំង ប្រយុទ្ធនឹង កម្លាំងបំផ្លាញជាតិខ្មែរ ត្រូវចាំបាច់មានរស្មី ជាប្រញាប់ នូវ កម្លាំង នៃចក្ខុវិស័យ, នៃដំណោះស្រាយ, នៃមនោគតិ ដើម្បី ប្រឈរមុខទល់នឹងសត្រូវជាតិ ព្រោះពេលវេលាកំពុងធ្វើការអោយវា។ តែបើខ្មែរ មិនដូរ ភាវៈ នៃ ព្រលឹងស្មារតី[7] នៃ ការមិនទទួលខុសត្រូវ លើវាសនា របស់ខ្លួន គឺ គ្រប់ការប្រឹងប្រែង ទាំងឡាយ ជា អំពើឥតប្រយោជន៍។ សន្តិភាព និង ឯករាជ្យជាតិ ដែលជា អត្តភាព នៃ ប្រជាជាតិខ្មែរ តម្រូវអោយមាន បដិវត្តន៍ នៃ ព្រលឹងស្មារតី ពីរយ៉ាង៖ ពលកម្ម និង ការទទួលខុសត្រូវ។ តើ ប្រជាពលរដ្ឋខ្មែរ មិនមែន ជា ឆ្មាំ នៃ សតិសម្បជញ្ញៈ នៃ ព្រលឹងស្មារតីជាតិ[8] នោះរឺ ? បើ ប្រជាពលរដ្ឋខ្មែរ នៅមាន សតិសម្បជញ្ញៈនោះ ដូច្នេះ ការធ្វើពលកម្ម ដើម្បី ប្រជាជាតិខ្លួន និង ការទទួលខុសត្រូវ លើវាសនាខ្លួនឯង វាជាកាតព្វកិច្ចជាតិ។ តែ សតិសម្បជញ្ញៈនោះ មិនមែនគ្រាន់តែជា សុបិនរហូត និង គតិបណ្ឌិត អស្ចារ្យ[9] មួយនោះឡើយ តែ វាជាការរក គន្លឹះ មានសុពលភាព នឹងធ្វើឲយើញត្រូវ, នឹងធ្វើឲមានការភ្ជាក់ស្មារតីជាតិ, នឹងធ្វើឲមានការរួបរួមជាតិ, នឹងកសាងមាគ៌ាជាតិ ជា ចិរកាល ព្រោះ ប្រជាជាតិខ្មែរ ជា ព្រលឹងអមតៈ៕

---

7 ភាវៈ នៃ ព្រលឹងស្មារតី ; l’état d’esprit។
8 ឆ្មាំ នៃ ព្រលឹងស្មារតីជាតិ ; gardien d’une conscience de l’esprit national។
9 Enchantement.